# លក្ខខន្តិកៈ

## ការធានារ៉ាប់រងលើការសម្រាកព្យាបាលនៅមន្ទីរពេទ្យស្មាត

**<u>នរណានឹងទទួលបានការធានា?</u>**

ការសម្រាកព្យាបាលនៅមន្ទីរពេទ្យស្មាត គឺត្រូវតែមានឈ្មោះនៅក្នុងគោលការណ៍ ដើម្បីទទួលបានការធានា, អតិថិជនដែលចុះឈ្មោះគឺត្រូវតែជាអតិថិជនប្រើប្រាស់ស៊ីមស្មាត។

**<u>អាយុៈ</u>**

អ្នកត្រូវតែមានអាយុចន្លោះពី 18-69ឆ្នាំ(ទាំងពីរត្រូវបានរាប់បញ្ចូល)។

**<u>ការកាត់ទឹកប្រាក់ នឹងការធានាៈ</u>**

- ការកាត់ទឹកប្រាក់បុព្វលាភ នឹងទទួលបានការធានារ៉ាប់រង 100% ដោយឥតគិតថ្លៃនៅក្នុងថ្ងៃដំបូងបន្ទាប់ពីការចុះឈ្មោះ ហើយការធានារ៉ាប់រងនេះគឺទទួលបានបន្ទាប់ពីមានការកាត់ទឹកប្រាក់បានជោគជ័យ។ ឧទាហរណ៍៖ ប្រសិនបើលក្ខិណាបានធ្វើការចុះឈ្មោះនៅថ្ងៃទី15 ខែមករា ហើយទឹកប្រាក់បុព្វលាភរបស់នាងគឺត្រូវបានកាត់ នឹងទទួលបានការធានារ៉ាប់រង 100%លើគ្រោះថ្នាក់ចៃដន្យនៅក្នុងថ្ងៃទី16 ខែមករា ហើយនាងក៏ទទួលបានការធានារ៉ាប់រងនៅក្នុងថ្ងៃទី1 ខែមិនា គឺអាស្រ័យលើចំនួនទឹកប្រាក់ដែលបានកាត់នៅខែមុន(ទាំងគ្រោះថ្នាក់ចៃដន្យ នឹងជំងឺ)។
- ប្រសិនបើចំនួនទឹកប្រាក់បុព្វលាភរ៉ាប់រងពេញលេញមិនត្រូវបានកាត់ក្នុងរយៈពេលមួយខែ នោះផ្នែកខ្លះនឹងត្រូវផ្តល់ជូនដោយផ្អែកលើចំនួនទឹកប្រាក់ជាក់ស្តែងដែលបានកាត់។
- ការទាមទារសំណងត្រូវបានទុករយៈពេលរហូតដល់ 3 ខែនៃការចូលសម្រាកព្យាបាលនៅមន្ទីពេទ្យ។

**<u>របៀបក្នុងការទាមទារសំណងៈ</u>**

- ដំណើរការនៃការទាមទារសំណង គឺធ្វើឡើងបន្ទាប់ពីឯកសារខាងក្រោមត្រូវបានដាក់ជូន៖
  A. ភស្តុតាងនៃការចុះឈ្មោះ (សារបញ្ជាក់ពីការចុះឈ្មោះ ឬការធានារ៉ាប់រង) ។
  B. ឯកសារបញ្ជាក់ពីអត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណ, សៀវភៅគ្រួសារ, ប័ណ្ណបើកបរ ឬលិខិតឆ្លងដែន) ។
  C. ព័ត៌មានលំអិតពីថ្ងៃចូល និងថ្ងៃចេញពីមន្ទីរពេទ្យ, ឈ្មោះអ្នកជំងឺ, អាយុ និងភេទ, ថ្ងៃនៃការជូនដំណឹង,ការអង្កេតដែរបានធ្វើរួច, ការព្យាបាលដែលបានផ្តល់ជូន មានត្រា នឹងហត្ថលេខាពីវេជ្ជបណ្ឌិត ឬវិក័យប័ត្រទូទាត់ និងវិក័យប័ត្រចុងក្រោយ) ។

## ករណីលើកលែងមិនផ្តល់សំណង:

ការទាមទារសំណងនឹងមិនត្រូវបានបង់ថ្លៃព្យាបាលនៅមន្ទីរពេទ្យដោយសារតែ៖

A. ការរងរបួសដោយខ្លួនឯង, ការប៉ុនប៉ងធ្វើអត្តឃាត ឬការព្យាបាលដែលមិនសមស្របទៅតាមដំបូន្មានវេជ្ជសាស្ត្រ
B. ការមានផ្ទៃពោះ
C. ការសេពគ្រឿងញៀន ឬគ្រឿងស្រវឹង
D. ល័ក្ខខ័ណ្ឌដែលមានពីមុន ឬកើតឡើងដដែលក្នុងរយៈពេលតែ 3 ខែដំបូងបន្ទាប់ពីចុះឈ្មោះ
E. សង្គ្រាម, ការលុកលុយសកម្មភាពរបស់សត្រូវ(មិនថាសង្គ្រាមត្រូវបានប្រកាស រឺអត់) សង្គ្រាមស៊ីវិល ការបះបោរ ឬបដិវត្តយោធា ឬដណ្តើមអំណាចធ្វើកូដកម្មកុបកម្មចលាចលស៊ីវិលអំពើភេរវកម្ម ឬផលវិបាកណាមួយ។
F. ជំងឺរាតត្បាត ដូចជាជំងឺ SARS ។ ល។
G. ការព្យាបាលដែលមិនស្របតាមវេជ្ជសាស្ត្រ, ការជ្រើសរើសការការពារ, ការជំនួសការព្យាបាល និងការវះកាត់កែសម្ផស្សរួមទាំងការព្យាបាលមាត់ធ្មេញ
H. ការមិនបង្ហាញពីស្ថានភាពសុខភាពមុនពេលចុះឈ្មោះ។ អ្នកដែលត្រូវបានធានារ៉ាប់រងគួរតែមានសុខភាពល្អ និងមិនមានជំងឺមុនការចុះឈ្មោះ។

## ការកាត់ផ្តាច់សេវាកម្ម:

គោលការណ៍នេះអាចត្រូវបានលុបចោលដោយទូរស័ព្ទទៅប៊ីម៉ាលេខ 010 242 248។ ការកាត់បុព្វលាភនឹងត្រូវបញ្ឈប់ក្នុងរយៈពេល 48 ម៉ោង។